# ការកាត់បន្ថយលទ្ធភាពនៃការទទួលប្រាក់លើសចំនួនកំណត់



## Reducing the Risk of Overpayment—Khmer

ការទទួលប្រាក់ Family Tax Benefit Part A (ប្រាក់បំណាច់ពន្ធដារគ្រួសារផ្នែក A) Family Tax Benefit Part B (ប្រាក់បំណាច់ពន្ធដារគ្រួសារផ្នែក B) ឬ Child Care Benefit (ប្រាក់បំណាច់ថែទាំកុមារ) (ជាថ្លៃកាត់បន្ថយ) ដែលលើសចំនួនត្រឹមត្រូវ អាចបណ្ដាលឲ្យមានការបារម្ភ ប៉ុន្តែជាការសំខាន់ក្នុងការចងចាំថា ការទទួលប្រាក់លើសនេះមិនមែនជាការចោទថាជាអំពើខុសនោះទេ។

ការទទួលប្រាក់លើសចំនួនកំណត់ ភាគច្រើនកើតមានឡើងដោយសារតែគ្រួសារទាំងឡាយប៉ាន់ស្មានប្រាក់ចំណូលរបស់ខ្លួនទាបជាងចំនួនពិតប្រាកដ។ គ្រួសារទាំងឡាយអាចមានប្រាក់ចំណូលច្រើនជាងការប៉ាន់ស្មាននៅក្នុងឆ្នាំហិរញ្ញកិច្ចមួយ ឧទាហរណ៍៖ ព្រោះអ្នកណាមួយបានធ្វើការងារថ្មីមានប្រាក់បៀវត្សរ៍ច្រើនជាងមុន មានការតម្លើងប្រាក់បៀវត្សរ៍ មានការផ្លាស់ប្ដូរចំនួនប្រាក់ឧបត្ថម្ភកូន ធ្វើការលើសម៉ោង ប្រាក់បន្ថែម ឬបើសមាជិកណាម្នាក់ទៀតក្នុងគ្រួសារបានចូលធ្វើការ។

## លោកអ្នកមានលទ្ធភាពខ្ពស់ក្នុងការទទួលប្រាក់លើសចំនួនកំណត់ បើគ្រួសារលោកអ្នកមាន៖

- មានប្រាក់ចំណូលចន្លោះ $42,000 និង $61,000; ឬ
- មានប្រាក់ចំណូលចំនួន $94,000 ឬច្រើនជាងនេះ; ឬ
- មានប្រាក់ចំណូលចំប៉ងចំនួន $140,000 ឬច្រើនជាងនេះ; ឬ
- អ្នកមានប្រាក់ចំណូលច្រើនជាងម្នាក់; ឬ
- ការផ្លាស់ប្ដូរប្រាក់ចំណូល ដោយសារតែការងារឬរពេលការធ្វើការ លើសម៉ោង ឬប្រាក់បន្ថែមមិនប្រក្រតី; ឬ
- ប្រាក់ចំណូលដែលលំបាកនឹងប៉ាន់ស្មាន ដោយសារតែលោកអ្នកជាអ្នកធ្វើការមិនទៀងទាត់ ធ្វើការយកកំរៃ ឬអាស្រ័យតាមកិច្ចសន្យា ឬបានទទួលប្រាក់បន្ថែមពីលើប្រាក់បើកឲ្យនៅពេលបញ្ឈប់មិនឲ្យធ្វើការតទៅទៀត; ឬ
- ប្រាក់ចំណូលបានមកពីអាជីវកម្ម ឬការប្រកបការងារដោយខ្លួនឯង; ឬ
- រួមទាំងកូនម្នាក់ដែលអាចរកប្រាក់បានចំនួន $12,287 ឬច្រើនជាងនេះ។

អត្រាប្រាក់ចំណូលទាំងអស់គឺត្រឹមត្រូវនៅថ្ងៃទី 01/07/2008។

ការទទួលប្រាក់លើសចំនួនកំណត់ក៏កើតមានផងដែរដោយសារតែកាលៈទេសៈគ្រួសារបានផ្លាស់ប្ដូរ ហើយមិនបានប្រាប់ Family Assistance Office (ការិយាល័យផ្ដល់ជំនួយដល់គ្រួសារ)។

## តើខ្ញុំកាត់បន្ថយលទ្ធភាពនៃការទទួលប្រាក់លើសចំនួនកំណត់តាមរបៀបណា?

### គិតអំពីការទទួលប្រាក់ប្រចាំឆ្នាំ

ប្រាក់បំណាច់ប្រចាំឆ្នាំនៃ Family Tax Benefit និង Child Care Benefit កាត់បន្ថយជាខ្លាំងនូវលទ្ធភាពនៃការទទួលប្រាក់លើសចំនួនកំណត់។ លោកអ្នកក៏អាចទទួលអត្រាគោលការណ៍នៃ Family Tax Benefit Part A ដែរ ហើយទទួលចំនួននៅសល់នៅដំណាច់ឆ្នាំដែលនឹងកាត់បន្ថយលទ្ធភាពនៃការទទួលប្រាក់លើសចំនួនកំណត់។

## បើប្រាក់បំណាច់ពេលពីរអាទិត្យម្ដងនៃ Family Tax Benefit និង Child Care Benefit ជាថ្លៃកាត់បន្ថយ មានភាពប្រសើរបំផុតសំរាប់គ្រួសារលោកអ្នក លោកអ្នកត្រូវ៖

### ធ្វើឲ្យប្រាកដថា លោកអ្នករក្សាការតាមសង្កេតមើលការប៉ាន់ស្មានប្រាក់ចំណូលរបស់លោកអ្នក

ដោយសារតែការផ្លាស់ប្ដូរទាំងអស់ដែលអាចកើតមានក្នុងគ្រួសារនានា លោកអ្នកត្រូវរក្សាការតាមសង្កេតមើលប្រាក់ចំណូលរបស់លោកអ្នក ហើយប្រាប់ Family Assistance Office ឲ្យដឹងអំពីការផ្លាស់ប្ដូរណាមួយទៅនឹងការប៉ាន់ស្មាននូវប្រាក់ចំណូលរបស់លោកអ្នក។ បើប្រាក់ចំណូលរបស់លោកអ្នកបានប្រែប្រួល លោកអ្នកអាចទទួលប្រាក់បំណាច់បន្ថែម ឬលោកអ្នកអាចទទួលប្រាក់នេះលើសចំនួនកំណត់។ បើលោកអ្នកទទួលប្រាក់ច្រើនជាងចំនួនដែលលោកអ្នកគួរទទួល គេនឹងសុំឲ្យលោកអ្នកសងប្រាក់លើសនេះមកវិញនៅដំណាច់ឆ្នាំហិរញ្ញកិច្ច។

We speak your language ✆ 13 1202

www.familyassist.gov.au

Australian Government
Family Assistance Office

ប្រាក់បើកលើសចំនួនកំណត់នៃ Family Tax Benefit និង Child Care Benefit ប្រហែលជាត្រូវបានទារយកវិញពីប្រាក់បំណាច់ Family Tax Benefit ឯទៀត រួមមានទាំងប្រាក់បន្ថែមនៅដំណាច់ឆ្នាំ។ ប្រាក់បើកលើសចំនួនកំណត់នៃ Family Tax Benefit ក៏ប្រហែលជាត្រូវបានទារយកវិញពីប្រាក់បង់ពន្ធលើសផងដែរ។ ជាការសំខាន់ណាស់ដែលលោកអ្នកនិងដៃគូលោកអ្នកដាក់របាយការណ៍បង់ពន្ធដារប្រចាំឆ្នាំរបស់លោកអ្នក(ឬប្រាប់ Family Assistance Office ប្រសិនបើលោកអ្នកមិនចាំបាច់ដាក់របាយការណ៍បង់ពន្ធដារប្រចាំឆ្នាំទេនោះ)។ ប្រាក់បើកលើសចំនួនកំណត់ទាំងអស់នឹងត្រូវបង់សងឲ្យគ្រប់ចំនួនវិញ។

## បើមានការផ្លាស់ប្តូរអ្វីមួយនោះ សូមចាត់ឲ្យមានសកម្មភាពទាន់ពេល

នេះគឺជាកិច្ចការសំខាន់បំផុតមួយដែលលោកអ្នកត្រូវធ្វើដើម្បីជួយ Family Assistance Office បើកប្រាក់ជូនលោកអ្នកឲ្យបានត្រឹមត្រូវ។

## នេះជាបញ្ជីឆែកមើលមួយនៃប្រការខ្លះដែលគួរតែរំលឹកលោកអ្នកឲ្យទូរស័ព្ទទៅ Family Assistance Office៖

- ការផ្លាស់ប្តូរប្រាក់ចំណូលគ្រួសារ ការងារថ្មី ការវិលទៅធ្វើការវិញ ការបាត់បង់ការងារ ការធ្វើការថែមម៉ោង ការឡើងប្រាក់បៀវត្សរ៍ កំណើននៃប្រាក់ចំណេញពីអាជីវកម្ម ប្រាក់ចំណេញពីការបណ្តាក់ទុន ទាំងអស់នេះធ្វើឲ្យមានការកែប្រែដល់ប្រាក់បំណាច់ដែលលោកអ្នកអាចទទួល។
- ការផ្លាស់ប្តូរស្ថានភាពមានគូស្រករ ឬនៅលីវរបស់លោកអ្នក។
- បើមានកូនចូលទៅក្នុង ឬចាកចេញពីបន្ទុកថែទាំរបស់លោកអ្នក។
- ការផ្លាស់ប្តូរប្រាក់ឧបត្ថម្ភកូន។
- បើលោកអ្នកចាកចេញពីប្រទេសអូស្ត្រាលី (ដោយមានរួមទាំងដំណើររយៈពេលខ្លី និងវិស្សមកាលផងដែរ)។
- ការប្រែប្រួលដល់ការរៀបចំថែទាំកូនរបស់លោកអ្នក។
- បើកូនណាមួយចាប់ផ្តើមចូល ឬចាកចេញពីសាលារៀន។
- បើមានការផ្លាស់ប្តូរដល់ការរួមចំណែកគ្នាក្នុងការថែទាំកូន។
- ប្រសិនបើលោកអ្នកយល់ថា កូនលោកអ្នកដែលមានអាយុលើសពី 16ឆ្នាំនឹងរកប្រាក់បានចំនួន $12,287 ឬច្រើនជាងនេះ។
- ការផ្លាស់ប្តូរអាសយដ្ឋានរបស់លោកអ្នក។

## ដើម្បីប្រាប់ Family Assistance Office អំពីការផ្លាស់ប្តូរណាមួយឬដើម្បីទទួលពត៌មានបន្ថែម៖

- ទូរស័ព្ទទៅកាន់ Family Assistance Office តាមលេខ **13 1202** រវាងម៉ោង 8:00ព្រឹក និង 5.00ល្ងាច (EST) ថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ ដើម្បីទទួលពត៌មានជាភាសាក្រៅពីអង់គ្លេស។
- បើកមើលវិបសៃ **www.familyassist.gov.au**
- អញ្ជើញទៅកាន់ Family Assistance Office (ការិយាល័យផ្តល់ប្រាក់ជំនួយដល់គ្រួសារ)លោកអ្នកនៅជិតជាងគេដែលស្ថិតក្នុងការិយាល័យ Medicare Australia, Centrelink,Customer Service Centres ហើយនិងកន្លែងទទួលភ្ញៀវនៃការិយាល័យពន្ធដារអូស្ត្រាលី។